ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីប្រកាសព័ត៌មាន
## ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន និងលោកជំទាវ Amanda Milling ពិភាក្សាអំពីកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី

នៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា បានផ្លាស់ប្តូរទស្សនៈ និងការពិភាក្សាជាមួយលោកជំទាវ Amanda Milling អនុរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអាស៊ី និងមជ្ឈិមបូព៌ា នៃក្រសួងការបរទេស កំមិនវែល និងអភិវឌ្ឍន៍ នៃចក្រភពអង់គ្លេស ដើម្បីលើកកម្ពស់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី នៅក្នុងឱកាសនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ និងកិច្ចប្រជុំពាក់ព័ន្ធ នៅរាជធានីភ្នំពេញ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន បានរំលឹកឡើងវិញអំពីដំណើរទស្សនកិច្ចជាលើកដំបូងរបស់លោកជំទាវ Amanda Milling មកកាន់កម្ពុជា កាលពីដើមខែមករា ឆ្នាំ២០២២ ដែលក្នុងឱកាសនោះ កម្ពុជា និងចក្រភពអង់គ្លេស បានបញ្ជាក់ពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការពង្រឹងបន្ថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងអន្តរជាតិ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន និងលោកជំទាវ Amanda Milling បានយល់ឃើញដូចគ្នាថា កម្ពុជា និងចក្រភពអង់គ្លេស មានទំនាក់ទំនងដ៏ល្អ និងបានស្នើថា គួររៀបចំសកម្មភាពរួមគ្នាដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧០ នៃការបង្កើតទំនាក់ទំនងការទូតរវាងកម្ពុជា និងចក្រភពអង់គ្លេស នៅក្នុងឆ្នាំក្រោយ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណចំពោះចក្រភពអង់គ្លេសដែលបានផ្តល់ប្រព័ន្ធអនុគ្រោះពន្ធ GSP ដល់កម្ពុជា ដែលបានរួមចំណែកដល់ការអភិវឌ្ឍទំនាក់ទំនងពាណិជ្ជកម្មរវាងកម្ពុជា និងចក្រភពអង់គ្លេស។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានកោតសរសើរចំពោះការបន្តផ្តល់ជំនួយរបស់ចក្រភពអង់គ្លេស ដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម សុខាភិបាល ការបោសសម្អាតមីន និងវិស័យអប់រំ។

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

នៅក្នុងក្របខ័ណ្ឌពហុភាគី ឯកឧត្តម ប្រាក់ សុខុន បានកោតសរសើរចំពោះកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-ចក្រភពអង់គ្លេស លើកទី១ និងបានថ្លែងអំណរគុណចក្រភពអង់គ្លេសចំពោះការគាំទ្រដល់ការធ្វើជាប្រធានអាស៊ានរបស់កម្ពុជានៅឆ្នាំ២០២២។ ភាគីទាំងពីរបានផ្លាស់ប្តូរទស្សនៈលើបញ្ហាតំបន់ និងអន្តរជាតិមួយចំនួន ដែលមានផលប្រយោជន៍ទៅវិញទៅមក និងជាកង្វល់រួម រាប់ចាប់ពីទំនាក់ទំនងអាស៊ាន-សហភាពអឺរ៉ុប និងអាស៊ាន-ចក្រភពអង់គ្លេស ស្ថានភាពនៅប្រទេសមីយ៉ាន់ម៉ា ការវិវត្តសន្តិសុខនៅឥណ្ឌូប៉ាស៊ីហ្វិក រហូតដល់វិបត្តិនៅប្រទេសអ៊ុយក្រែន៕

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០២២

អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

**ជុំ សុន្ទរី**